ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៦ សរណន

# សារាចរណែនាំ

# ស្តីពី

# គោលការណ៍អនុវត្តចំណាយលើសោហ៊ុយបេសកកម្មក្រៅប្រទេស

ក្នុងគោលដៅដើម្បីធានាបាននូវការគោរពវិន័យថវិកា ការបង្កើនប្រសិទ្ធភាពចំណាយថវិកា និងការសន្សំសំចៃលើមុខចំណាយបេសកកម្មក្រៅប្រទេស ក៏ដូចជាក្នុងបរិការណ៍ដែលកម្ពុជាបាននិងកំពុងជួបប្រឈមនឹងហានិភ័យនានាជាបន្តបន្ទាប់ ដែលមានបច្ច័យអវិជ្ជមានដល់ការប្រមូលចំណូល និងលទ្ធភាពចំណាយថវិការដ្ឋជារួម រាជរដ្ឋាភិបាល សូមធ្វើការណែនាំនិងដាក់ចេញនូវវិធានការម៉ឹងម៉ាត់ដល់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលអនុវត្តមុខចំណាយបេសកកម្មក្រៅប្រទេស ដូចខាងក្រោម÷

(១)- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តចំណាយបេសកកម្មក្រៅប្រទេសត្រឹមកម្រិតឥណទានអតិបរមាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវទូទាត់ឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ហើយសម្រាប់សកម្មភាពដែលអនុវត្តនៅចុងឆ្នាំថវិកា អាចទូទាត់បាននៅត្រឹមត្រីមាសទី១ នៃឆ្នាំថវិកាបន្ទាប់។

(២)- មិនអនុញ្ញាតឱ្យអនុវត្តចំណាយមុន លើបេសកកម្មក្រៅប្រទេស ដោយមិនមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និង/ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ក្នុងករណីនៅតែបន្តមាន ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលខុសត្រូវក្នុងការដោះស្រាយចំណាយនេះដោយផ្ទាល់ក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់ខ្លួន។

(៣)- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវបង្កើនការសន្សំសំចៃលើចំណាយបេសកកម្មក្រៅប្រទេស ដោយផ្អាកសកម្មភាពចូលរួម ឬផ្អាកការរៀបចំព្រឹត្តិការណ៍ក្រៅប្រទេសដែលមិនចាំបាច់ មិនសូវចាំបាច់ និងលែងចាំបាច់ ហើយត្រូវចូលរួម ឬរៀបចំតែសកម្មភាពឬព្រឹត្តិការណ៍ណាដែលចាំបាច់ខ្លាំង និងសកម្មភាពដែលជាកាតព្វកិច្ចតាមវេន ហើយអាចនាំមកនូវផលប្រយោជន៍ជាក់លាក់ដល់ប្រទេសជាតិ។



ហ

ទន្ទឹមនេះ រាជរដ្ឋាភិបាល សូមលើកទឹកចិត្តឱ្យក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ បង្វែរសកម្មភាព ឬព្រឹត្តិការណ៍នានា មកធ្វើតាមប្រព័ន្ធអនឡាញ (Online) វិញ ទៅតាមលទ្ធភាពជាក់ស្តែង។

(៤)- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវណែនាំដល់ប្រធានអង្គភាព និងមន្ត្រីក្រោមឱវាទ ឱ្យចាត់វិធានការរឹតបន្តឹងការគ្រប់គ្រងចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេសឱ្យបានម៉ឺងម៉ាត់ និងក្នុងស្មារតីសន្សំសំចៃខ្ពស់។

គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធិភាព និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៩ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល÷</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

-រដ្ឋបាលក្រុង-ស្រុកទាំង១៤ នៃខេត្តបាត់ដំបង

"ដើម្បីមុខការ"